# របាំកាប់ក្របីផឹកស្រា

ព្រះរាជាណាចក្រកម្ពុជា សម្បូណ៌ទៅដោយជនជាតិដើមភាគតិច ដែលរស់នៅក្នុងតំបន់ខ្ពង់រាបតាមដងភ្នំក្រ៉ាញ ភ្នំឱ៉ាល់ ភ្នំដងរែក និងតំបន់ភ្នំផ្នែកទិសឦសានក្នុងខេត្តមណ្ឌលគិរីនិងរតនគិរី។ ជនជាតិដើមភាគតិចទាំងនេះ មានស្អូច ស្ទៀង ក្រោល សម្រែ រ៉ាអុង (រអួង) ព័រ សួយ គួយ ត្រឹង ទំពួន លុន ចារ៉ាយ ព្រៅ កាចក់ កាវ៉ែត ថ្ងូន ស្ទឹល ជង អាណុង រ៉ូដេរ ខា និងព្នង។ល។

ជនជាតិដើមភាគតិច មានវប្បធម៌ពិសេសរៀងៗខ្លួនប្រចាំក្រុមនិងជាតិសាសន៍របស់ខ្លួន រួមទាំងតន្ត្រីនិងរបាំ។ ឧបករណ៍តន្ត្រីរបស់គេ មានៈ ពួយ មុិម ហ្គងណាក់ (រនាតបំពង់ប្រស្សីតូចៗ) កាណី (ទ្រឃ្វោក) ប្រក (កូតប្ទដេញក៏បាន) ហ្គងទីង ហ្គងរីង (កេះប្ទដេញ) ហ្គង-ប (កំណាត់ប្រស្សីវាយផ្ទប់នឹងដីឲ្យព្ទសូរ) ដ្ឋូ (ខ្ទុយ) ហេតហូត (បំពង់ប្រស្សីតូចៗចងភ្ជាប់គ្នាផ្ទុំជាសូរ) ប៊ុមប៊ុក (ប្រស្សីទៈ) ជីងរៀង (ចាប៊ីឃ្វោក) គងញីនិងគងឈ្មោល ព្រមទាំងវង់គង៣ផ្ទៃ ៥ផ្ទៃ ៧ផ្ទៃ ១២និង១៣ផ្ទៃ។ ឯរបាំក៏មានច្រើន ដូចជារបាំយុវ័នរួមសាមគ្គី របាំប៊ុនហ៊ា របាំរាំវង់ភូមិថ្មី របាំសែនភូមិ របាំភោគផល និងរបាំកាប់ក្របី(ផឹកស្រា) ជាដើម។

នៅក្នុងចំណោមជនជាតិដើមភាគតិចនៅភូមិភាគឦសាននៃប្រទេសកម្ពុជា គេតែងប្រារព្ធធ្វើពិធីកាប់ក្របីដើម្បីថ្វាយជូនទៅព្រលឹងអារក្ខអ្នកតាក្នុងជំនឿអរូបីរបស់គេ។ នៅក្នុងពិធីដែលគេរៀបចំឡើង អ្នកភូមិមានចាស់មានក្មេងវាយគងនិងរាំច្រៀងជាក្រុម។

ជាពិសេសនៅពេលច្រូតកាត់រួចហើយ នៅក្នុងទំនៀមទម្ងាប់របស់គេ អ្នកភូមិរៀបចំធ្វើពិធីកាប់ក្របី ដើម្បីថ្វាយកតញ្ញូតាធម៌ចំពោះព្រលឹងអារក្ខអ្នកតានិងវត្ថុស័ក្តិសិទ្ធអ្នកថែរក្សាគេ និងអបអរសាទរចំពោះផលិតផលសម្បូណ៌ហូរហៀរដែលគេទើបតែនឹងច្រូតកាត់រួច។ នៅក្នុងឱកាសជប់លៀងពេលថ្ងៃឬល្ងាច គេផឹកស្រាពាងបិទនិងរាំលេងកម្សាន្ត ដើម្បីឱ្យមានសុខដុមភាពជាមួយនឹងព្រលឹងអារុក្ខអារក្ខអ្នកតានិងវត្ថុស័ក្តិសិទ្ធដែលថែរក្សាគេ។ នៅពេលនេះដែរ ដែលគេបូជាក្របី ហៅថា «ពិធីកាប់ក្របី»។

អត្ថបទដោយៈ បណ្ឌិត សំ សំអាង

AMS

របាំកាប់ក្របី ឬ របាំកាប់ក្របីផឹងស្រា រាំដោយអ្នករាំសុទ្ធតែប្រុស កំដរដោយវង់តន្ត្រីគង១២ឬ១៣ផ្ទៃ ដែលបង្ហាញនូវភាពមាំមួន រឹងប៊ឹង កម្ទាំងខ្ទាំងក្លា និងឥទ្ធិពលទៅតាមចលនានៃការបរបាញ់ សកម្មភាពប្រមាញ់សត្ទ ដោយទន្ទ្រាំជើងខ្ទាំងៗទៅលើដី និងផឹកស្រាពាង ទៅតាមចង្វាក់នៃសូរវង់គង។ នាបុរាណកាល នៅក្នុងអំឡុងនៃពិធីនេះ បន្ទាប់ពីពិធីបានប្រារព្ធធ្វើរួចចប់សព្ទគ្រប់ហើយ គេក៏នាំគ្នាចេញទៅបរបាញ់សត្ទ។

ក្រៅពីអត្ថន័យខ្ទឹមសាររក្សាទំនៀមទម្ទាប់ប្រពៃណីនិងជំនឿរបស់គេ របាំកាប់ក្របីផឹកស្រា លាតត្រដាងពីជីវិតប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចដែលបង្កប់នូវអត្ថន័យសំខាន់នៃចំណងសហគមន៍ដ៏រឹងមាំ ដូចដែលឆ្ទុះបញ្ចាំងដោយការរួបរួមគ្នាជាក្រុម និងវង់តន្ត្រីវាយគងទាំង១២ឬ១៣ផ្ទៃ។ នៅក្នុងន័យនេះ គឺទាល់តែមានអ្នកចូលរួមទាំងអស់គ្នាជាក្រុម និងជាវង់តន្ត្រី ទើបគេអាចលេងភ្ជងបាន។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ឯកសារពិគ្រោះ

ពេជ្រ ទុំក្រវ៉ិល.

(២០០៣). *ទស្សនីយភាពខ្មែរ*. ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

Keo, Phuong. (2001). *Tourism Resort of Cambodia*. Phnom Penh: Ministry of Tourism.

_____. (2003). *Tourism Sites of Cambodia*. Phnom Penh: Ponloeu Khmer Printing and Publishing House.

Sam, Sam-Ang. (2002). *Musical Instruments of Cambodia*. Osaka: National Museum of Ethnology.

Sam, Sam-Ang, Yun, Khean, and Chhim, Naline. (2010). *Music in the Lives of the Indigenous Ethnic Groups in Northeast Cambodia*. Phnom Penh: PUC Press.